# រឿង មហាចោរនៅទល់ដែន

## ភាគទី៣៣ (ព្រះនាងខត្តិយាណី)

ថាតែប៉ុណ្ណោះនារីចាប់ដឹកដៃកាមាឡើងទៅលើជណ្តើរវិញ។ កាមាក៏ទៅតាមនាង។ ដល់មាត់ទ្វារខាងលើ នារីបិទទ្វារវិញយ៉ាងជិត។ មានន្ទនៅស្ងៀមជាយូរមកហើយ។ ស្រីដ៏ល្អនេះជាអ្នកណា? គឺព្រះនាងខត្តិយាណី "កែវមណី" ប្អូនជីដូនមួយមានន្ទបង្កើត។ ឪពុកនារីធ្វើចៅហ្វាយខេត្តនៃចង្វាត់សុរិន្ទ្រ។ តាំងពីតូចមកនាងមកនៅជាមួយព្រះកម្ពុត ដែលត្រូវជាឪពុកមារបស់នាង។ តែចំនួនប្រាំឆ្នាំហើយ នាងបានចាកចេញពីគេហដ្ឋានមកនៅជាមួយព្រះកម្ពុតវិញ។ ថ្ងៃដែលនាងមកមានក្បួនដំរី សេះ និងកងសេនាជាច្រើន ជូនមកយ៉ាងអឹកធឹក។ អាយុទើបបានដប់ប្រាំបីឆ្នាំ នារីមានរូបរាងកាយល្អឥតគណនា។ ប្រថាប់លើខ្នងដំរី ស្ត្រីមានទឹកមុខញញឹមប្រិមប្រិយដោយនាងនឹកដល់អនុស្សាវរីយ៍ចាស់របស់នាងជាមួយមានន្ទ។ កាលនៅកុមារនៅឡើយ គឺមានន្ទនេះឯង ដែលដឹកដៃនាងទៅរៀន ដែលការពារនាងមិនឲ្យសត្រូវមើលងាយ ដែលពរនាងទាំងត្រដាបត្រដួសរកបេះអស់ផ្លែត្របែក ផ្លែល្ហុងឲ្យនាងបរិភោគ។ ដល់អាយុដប់ឆ្នាំនាងនិងមានន្ទមានចិត្តរាប់អានគ្នាទៅវិញទៅមកយ៉ាងជ្រាលជ្រៅ។

នារីនឹកឃើញពាក្យសំដីរបស់មានន្ទ ដែលនិយាយជាមួយនាងថា: "កុំលះបង់ចោលគ្នា"។ ដល់អាយុ១៣ឆ្នាំ នាងលាមានន្ទទៅផ្ទះឪពុកនាងវិញ។ ថ្ងៃនោះស្ត្រីព្រួយបារម្ភខ្លាំងក្រៃលែង នាងអោបស្មាមានន្ទដោយមិនចង់បែកឃ្លាតសោះ។

តាំងពីបានជួបនឹងប្រុសកំសត់នេះមក នាងអស់ចិត្តនឹងគិតដល់រូបអ្នកណាទៀតហើយ ពីព្រោះក្នុងជីវិតនាងរហូតមកនេះ ធីតាពុំដែលជួបប្រទះនឹងប្រុសណាឲ្យមានសំដីពិរោះ មានបញ្ញាដូចមានន្ទសោះ មានន្ទមានឧត្តមគតិខ្ពស់ ចិត្តស្លូតត្រង់ ប្រកបដោយសេចក្តីក្លាហានអង់អាច។

សេចក្តីរាប់អានរបស់នាងនេះ បានកើតឡើងដោយស្ទាត់កំបាំងទេ។ គ្មានចាស់ទុំណាដឹងឮសោះឡើយ។ ធីតានៅទីក្រុងសុរិន្ទ្រគ្មានពេលណាបានសុខសប្បាយម្តងណាឡើយ។

អត្ថបទដោយ៖ មាស សុភាព

នៅមុខគេឯងនាងធ្វើជារីករាយសប្បាយ។ នៅម្នាក់ឯងនាងព្រួយយំដោយនឹករលឹកដល់ប្រសុដីវ៉ា។

កាលមកដល់ប្រាសាទព្រះកម្ពុតក្វាម នាងស្រងាកចិត្តដោយរកមានន្ទមិនឃើញសោះ។ នាងសួរឪពុកមានាង ឪពុកមានេះបាននិយាយជេរមានន្ទយ៉ាងខ្លាំង ដោយចាត់ទុកថាជាមនុស្សក្បត់ផែនដី រួចឪពុកមានាងកំពុងរកចាប់សម្លាប់ចោល។

ស្ត្រីអស់សង្ឃឹមនឹងបានជួបប្រុសជាមិត្តនេះហើយ ដោយហេតុរឿងបដិបក្ខក្នុងគ្រួសារបែបនេះ។ នាងអាឡោះអាល័យ អាណោចអាធមនឹងវាសនានាងជាមួយមានន្ទដែលពិតជាគូកម្មនឹងគ្នាប្រាកដ។

លង់ក្នុងសមុទ្រទុក្ខមួយយ៉ាងធំ ព្រះនាងខត្តិយាណីគិតនឹងសុំលាព្រះកម្ពុតត្រលប់ទៅទីលំនៅវិញតែគាប់ជួនយប់មិញនេះ គេថាចាប់មហាចោរនៅទល់ដែនមួយបានហើយ។ នាងសាកសួរគេទៅ ទើបដឹងថា មហាចោរនៅទល់ដែននេះគឺមានន្ទ។

ព្រះនាងខត្តិយាណីមិនពេញចិត្តនឹងមានន្ទធ្វើដូច្នេះសោះ ពីព្រោះនាងមានមនោសញ្ចេតមួយដូចអស់នារីភាគច្រើន គឺចង់ឲ្យមានន្ទធ្វើការមានមុខមានមាត់ទៅ រួចរៀបបរិវាហមង្គលការជាមួយនាង។ ប្រព្រឹត្តខុសពីនេះដោយតស៊ូច្បាំង គ្មានផ្ទះ សម្បែង ចោលបុណ្យសក្តិគឺផ្ទុយនឹងលំអានលោក។ នាងប្រាថ្នាចង់រស់ជីវិតមួយដ៏សុខសាន្តដែលគ្មានរឿងរ៉ាវធំ។ កិច្ចការដែលមានន្ទពុះពារជាកិច្ចការស្លាប់រស់គ្មានទំនេរគ្មានបានសុខដូចចិត្តនាងចង់នោះទេ។ នាងរមិលមើលឃើញថា បំណងរបស់សង្សារនាងនេះ ខុសនឹងបំណងនាង ហើយបំណងនេះមិនបានសម្រេចជាដាច់ខាត។

នេះជាឧបសគ្គដែលធ្វើចិត្តនាងឲ្យបែកចេញពីមានន្ទ។ រីឯមានន្ទកាលដែលឃើញនាងកែវមណីជាប្អូនសួនបណ្តូលចិត្តចាស់បុរសស្រឡាំងកាំង។ អ្នកនឹកឆ្ងល់ណាស់ដែរតែពេលនឹកកន្ទែងមិនសមឲ្យអ្នកទទួលនាងដោយសេរីបានសោះ។ អ្នកអង្គុយចុះដោយចិត្តខ្ពលខ្នាញ់យ៉ាងក្រៃលែង។

អត្ថបទដោយ៖ មាស សុភាព

បុរសនឹកថាស្រីនេះមានជីវិតខ្ពស់ ធ្លាប់តែឃើញវត្ថុល្អៗ ដល់មកឃើញអ្នកជាប់ខ្នោះក្នុងបាតគុកយ៉ាងនេះ ប្រាកដជានារីមើលងាយខ្ពើមរអើមមិនខាន។

តម្លៃដែលស្រីស្រស់ច្នៃឃើញនោះ គឺបុណ្យសក្តិ មាសពេជ្រ។ រីឯតម្លៃនៃចិត្តខ្ពស់ពិតៗនោះ ធីតាជាសង្សារបូរាណ មើលមិនឃើញទេ។

កំពុងតែគិតដូច្នោះ កែវមណីធីតាលេចចូលមក។ នាងញញឹមចុះដណ្តើរស្ទើរដួលដោយរវល់តែមើលមកមាននុ។

លុះមកដល់ជិតនាងអង្គុយលើគ្រែ យកដៃកាន់ស្មាអ្នកទោសយើងដោយនិយាយសំឡេងឡើងញ័រៗថា:

ប្អូនសូមជម្រាបសួរបង។ បងសុខសប្បាយជាទេ?

មិនបានសុខទេ គ្មានសប្បាយទេ។

ពីព្រោះអ្វី?

ពីព្រោះជាប់គុក ដៃជើងជាប់ច្រវ៉ាក់!

ហ៊ឺ! កុំនិយាយដូច្នោះ ប្អូននឹករលឹកដល់បងខ្លាំងណាស់។

(សូមរង់ចាំតាមដានភាគទី៣៤ នៅសប្តាហ៍ក្រោយ)

KHMER CIVILIZATION

អត្ថបទដោយ៖ មាស សុភាព